**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៥.០៣២/១៣ គ.ជ.ប.អគ្គ.ពស**

រាជធានីភ្នំពេញ ថ្ងៃទី 18 ខែឧសភា ឆ្នាំ២០១៣

## ក្រសួងមហាផ្ទៃ និង គ.ជ.ប ចេញសេចក្តីណែនាំរួមបន្ថែមស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣

កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានចេញសេចក្តីណែនាំរួមបន្ថែមលើសេចក្តីណែនាំរួមលេខ ០២៣ សណន ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត ។

សេចក្តីណែនាំរួមបន្ថែមនេះ ត្រូវបានកែសម្រួលនិងណែនាំបន្ថែមលើសេចក្តីណែនាំរួមលេខ ០២៣ សណន ចុះថ្ងៃ ទី១៣ ខែកក្កដា ឆ្នាំ២០១១ មានដូចខាងក្រោម ៖

- ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត នៅមុនថ្ងៃបោះឆ្នោតលើកនេះ ត្រូវបានកែសម្រួលឱ្យបញ្ចប់ត្រឹមថ្ងៃសុក្រ ទី១២ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ៥:៣០នាទីល្ងាច ជាកំហិត ។
- នៅពេលបញ្ចប់ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត មេឃុំ ចៅសង្កាត់ត្រូវធ្វើរបាយការណ៍បូកសរុបលទ្ធផលតាមនីតិវិធី ក្នុងនោះត្រូវបិទផ្សាយជាសាធារណៈជាបន្ទាន់នៅសាលាឃុំ សង្កាត់ និងផ្ញើជូនគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(គឃ/សប)នៃឃុំ សង្កាត់របស់ខ្លួន ។
- នៅពេលបញ្ចប់ការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត មេឃុំ ចៅសង្កាត់ត្រូវវេចខ្ចប់សៀវភៅបញ្ជីលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត រួចបញ្ជូនមកគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(គធ/ខប) ជាបន្ទាន់ ដើម្បីរក្សាទុក ។
- នៅពេលទទួលបានរបាយការណ៍បូកសរុបអំពីលទ្ធផល នៃការចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតពីមេឃុំ ចៅសង្កាត់ គឃ/សប ត្រូវធ្វើការបិទផ្សាយជាសាធារណៈជាបន្ទាន់នៅទីស្នាក់ការរបស់ខ្លួន ។
- គធ/ខប ត្រូវសហការចាត់ចែងទទួលយកគល់បញ្ជី និងសៀវភៅលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតពីមេឃុំ ចៅសង្កាត់ឱ្យបានទាន់ពេលវេលា និងត្រូវរក្សាទុកឱ្យបានគត់មត់ ។ គធ/ខប ត្រូវអនុញ្ញាតឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតពិនិត្យមើលគល់បញ្ជី និងសៀវភៅលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត តាមការស្នើសុំ ៕ក